ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ........................សហវ.

# សេចក្តីណែនាំ

## ស្តីពី

## ការដាក់ឱ្យអនុវត្តមុខងាររៀបចំផែនការថវិកា នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ក្រសួង-ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ចាប់ពីឆ្នាំ ២០២៣

គិតត្រឹមឆ្នាំ ២០២២ កន្លងទៅនេះ មុខងាររៀបចំផែនការថវិកានៃប្រព័ន្ធ FMIS បានដាក់ឱ្យអនុវត្តរួចហើយនៅតាមអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ នៃក្រសួង-ស្ថាប័នចំនួន ១៣ រួមទាំងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ មុខងាររៀបចំផែនការថវិកាមានអនុមុខងារចំនួន ៩ គឺ÷ ១-អនុមុខងាររៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, ២-អនុមុខងាររៀបចំក្របខណ្ឌថវិការយៈពេលមធ្យម, ៣-អនុមុខងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា, ៤-អនុមុខងាររៀបចំចំណូលថវិកា, ៥-អនុមុខងាររៀបចំចំណាយថវិកា, ៦-អនុមុខងាររៀបចំប្រាក់បៀវត្សមន្ត្រីរាជការ, ៧-អនុមុខងាររៀបចំសូចនាករសមិទ្ធកម្ម, ៨-អនុមុខងាររៀបចំចំណាយថវិកាមូលធន និង ៩-អនុមុខងាររៀបចំចំណាយថវិកាការទូទាត់ការខ្ចី ។

ស្របតាមផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី៣ ២០២១-២០២៥, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តពង្រីកការដាក់ឱ្យអនុវត្តប្រើប្រាស់មុខងាររៀបចំផែនការថវិកាទៅកាន់ក្រសួង-ស្ថាប័នចំនួន ១២ បន្ថែមទៀត, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំងអស់ (ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ) ចាប់ពីឆ្នាំ ២០២៣ តទៅ ។

ដូចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹង និង ណែនាំដល់ក្រសួង-ស្ថាប័នទាំង ១២, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំងអស់ អំពីការអនុវត្តមុខងាររៀបចំផែនការថវិកានៃប្រព័ន្ធ FMIS ដូចតទៅ÷

### ១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១.១. ***អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត*** កត់ត្រាផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិលរបស់ក្រសួង-ស្ថាប័នខ្លួន ឬ អង្គភាពខ្លួននៅក្នុងប្រព័ន្ធ បន្ទាប់ពីបានបូកសរុបនិងអនុម័តរួចរាល់ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

១.២. **នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ធ្វើការត្រួតពិនិត្យ និង វាយតម្លៃទៅលើផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ដែលបានរៀបចំរួចនៅក្នុងប្រព័ន្ធ ។

## ២. ការរៀបចំផែនការថវិកា

**<u>ការអនុវត្តនៅក្រសួង-ស្ថាប័ន</u>**

២.១. ***អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ*** កត់ត្រា និង អនុម័តលើ សូចនាករ គោលដៅសូចនាករ គម្រោងចំណូលថវិកា និង គម្រោងចំណាយថវិកា (រួមទាំង គម្រោងចំណាយបៀវត្សនិងបន្ទុកបុគ្គលិក) នៅក្នុងប្រព័ន្ធ រួចបញ្ជូនទៅកាន់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ។

២.២. ***អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ*** ធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង អនុម័ត លើសូចនាករ គោលដៅសូចនាករ គម្រោងចំណូលថវិកា និង គម្រោងចំណាយថវិកា (រួមទាំង គម្រោងចំណាយបៀវត្សនិងបន្ទុកបុគ្គលិក) ប្រចាំឆ្នាំរបស់អង្គភាពថវិកានីមួយៗដែលបានបញ្ជូនតាមប្រព័ន្ធ ព្រមទាំងកត់ត្រា និង អនុម័តលើ សូចនាករ គោលដៅសូចនាករ គម្រោងចំណូលថវិកា និង គម្រោងចំណាយថវិកា (រួមទាំង គម្រោងចំណាយបៀវត្សនិងបន្ទុកបុគ្គលិក) ប្រចាំឆ្នាំរបស់អង្គភាពថវិកាផ្សេងទៀតដែលមិនទាន់ប្រើប្រាស់ប្រព័ន្ធ រួចបូកសរុបជារួមសម្រាប់ក្រសួង-ស្ថាប័នរបស់ខ្លួន បញ្ជូនតាមប្រព័ន្ធទៅកាន់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**<u>ការអនុវត្តនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ</u>**

២.៣. ***មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត*** កត់ត្រា និង អនុម័តលើ សូចនាករ គោលដៅសូចនាករ គម្រោងចំណូលថវិកា គម្រោងចំណាយថវិកា (រួមទាំង គម្រោងចំណាយបៀវត្សនិងបន្ទុកបុគ្គលិក) ប្រចាំឆ្នាំរបស់ខ្លួននៅក្នុងប្រព័ន្ធ រួចបញ្ជូនទៅកាន់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**<u>ការអនុវត្តនៅអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ</u>**

២.៤. **នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ធ្វើការបញ្ចូលអត្រាប្រាក់បៀវត្ស និង បន្ទុកបុគ្គលិកផ្សេងៗរបស់មន្ត្រីរាជការទៅក្នុងប្រព័ន្ធ ដើម្បីក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តរៀបចំគម្រោងចំណាយបៀវត្សមន្ត្រីរាជការនៅក្នុងប្រព័ន្ធ ។

២.៥. **នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ធ្វើការពិនិត្យឱ្យបានហ្មត់ចត់ កែសម្រួល និង អនុម័តនៅក្នុងប្រព័ន្ធ លើសូចនាករ គោលដៅសូចនាករ គម្រោងចំណូលថវិកា និង គម្រោងចំណាយថវិការបស់ក្រសួង-ស្ថាប័ន ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាបន្តបន្ទាប់ទៅតាមដំណាក់កាលនីមួយៗនៃការពិភាក្សា ចរចា និង អនុម័តថវិកា ។

២.៦. **នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បញ្ចូលផែនការថវិកាដែលទទួលបានការអនុម័តចុងក្រោយ (ច្បាប់ថវិកា) របស់ក្រសួង-ស្ថាប័ន-អង្គភាព ដែលមិនទាន់បានប្រើប្រាស់មុខងាររៀបចំផែនការថវិកា ទៅក្នុង ប្រព័ន្ធតែម្តង ។

**សម្គាល់÷** សម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៤ ខាងមុខ ក្រសួងចំនួន ២ រួមមាន÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន នឹងត្រូវចាប់ផ្តើមអនុវត្តសាកល្បងការចរចាថវិកាតាមប្រព័ន្ធ (មុខងាររៀបចំផែនការថវិកា) ដោយអនុវត្តកិច្ចប្រជុំចរចាថវិកាតាមប្រព័ន្ធត្រឹមកម្រិតបច្ចេកទេសសិន ។ ដូចនេះ ក្រសួងទាំង ២ ចាំបាច់ត្រូវបញ្ចូលគម្រោងថវិកាចាប់តាំងពីដំណាក់កាលរៀបចំផែនការយុទ្ធសាស្ត្រថវិកា រហូតដល់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ទៅតាមមុខងារពាក់ព័ន្ធនីមួយៗនៅក្នុងប្រព័ន្ធ។

ក្រសួង-ស្ថាប័នទាំង ១២, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធនានាត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល÷</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- ក្រសួង-ស្ថាប័នចំនួន ១២ (ដូចមានក្នុងឧបសម្ព័ន្ធ)
- អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ ០៧ សហវ.អគរ.អ៧ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣**

# ស្តីពី

# ការដាក់ឱ្យអនុវត្តមុខងាររៀបចំផែនការថវិកា
# នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
# សម្រាប់ក្រសួង-ស្ថាប័នចំនួន ១២, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង
# មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ចាប់ពីឆ្នាំ ២០២៣

## វិហ្វូវនៃការប្រើប្រាស់មុខងាររៀបចំផែនការថវិកានៃប្រព័ន្ធ FMIS

*១.វិហ្វូវនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត*

ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត




*២.វិហ្វូវនៃការរៀបចំផែនការថវិកាពីអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ អង្គភាពទទួលបន្ទុកក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និង អគ្គនាយកដ្ឋានថវិកា*

ការរៀបចំផែនការថវិកាប្រចាំឆ្នាំ



### ៣.វិហ្វូរនៃការរៀបចំផែនការថវិកាពីការអនុម័តថវិកាកម្រិតបច្ចេកទេស កម្រិតថ្នាក់ដឹកនាំ និង ស្ថាប័នកំពូលរហូតដល់ច្បាប់ថវិកាប្រចាំឆ្នាំ



**ឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំលេខ ០០២ សហវ.សលក.អក ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២៣**

# ស្តីពី ការដាក់ឱ្យអនុវត្តមុខងាររៀបចំផែនការថវិកា
# នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
# សម្រាប់ក្រសួង-ស្ថាប័នចំនួន ១២, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង
# មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ចាប់ពីឆ្នាំ ២០២៣

## ក.បញ្ជីឈ្មោះក្រសួង-ស្ថាប័នចំនួន ១២ បន្ថែមថ្មី

| | |
|---|---|
| ១.អាជ្ញាធរសវនកម្មជាតិ | ៧.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា |
| ២.អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | ៨.ក្រសួងទេសចរណ៍ |
| ៣.អគ្គលេខាធិការដ្ឋានរដ្ឋសភា | ៩.រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ៤.ក្រសួងធនធានទឹក និងឧតុនិយម | ១០.ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ |
| ៥.ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ១១.តុលាការកំពូល |
| ៦.ក្រសួងពាណិជ្ជកម្ម | ១២.សាលាឧទ្ធរណ៍ |

## ខ.បញ្ជីឈ្មោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៧ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| | |
|---|---|
| ១.អគ្គលេខាធិការដ្ឋាន | ១១.វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ២.អគ្គនាយកដ្ឋានគោលនយោបាយ | ១២.អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| ៣.អគ្គនាយកដ្ឋានថវិកា | ១៣.និយ័តករធានារ៉ាប់រងកម្ពុជា |
| ៤.អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៤.និយ័តករបរធនបាលកិច្ច |
| ៥.អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | ១៥.និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ |
| ៦.អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | ១៦.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា |
| ៧.អគ្គាធិការដ្ឋាន | ១៧.អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| ៨.អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | |
| ៩.អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | |
| ១០.អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | |